Time to screen

BreastScreen Aotearoa

ភាសាខ្មែរ (Khmer)

ឥឡូវនេះ អ្នកបានថតម៉ាម៉ូក្រាមរួចរាល់ហើយ

TimeToBreastScreen.nz

សូមអរគុណសម្រាប់ការចូលរួមក្នុងកម្មវិធី BreastScreen Aotearoa ។ អ្នកអាចឆ្ងល់ថាតើនឹងមានអ្វីកើតឡើងបន្ទាប់ ។ ខិត្តប័ណ្ណនេះ ពន្យល់អំពីដំណើរការនេះ ។

រូបថតម៉ាម៉ូក្រាមរបស់អ្នក នឹងត្រូវបានពិនិត្យដោយយកចិត្តទុកដាក់ ពីអ្នកជំនាញខាងវិទ្យុសកម្មពីររូប (គ្រូពេទ្យដែលមានជំនាញក្នុងការមើលរូបភាពម៉ាម៉ូក្រាម) ។ ប្រសិនបើកម្មវិធីនេះ បានថតម៉ាម៉ូក្រាមពីមុនជូនអ្នក គេនឹងធ្វើការប្រៀបធៀបរូបទាំងនេះ ដើម្បីពិនិត្យមើលការផ្លាស់ប្តូរណាមួយដែលអាចកើតឡើង ។

លទ្ធផល នឹងត្រូវផ្ញើដោយផ្ទាល់ទៅអ្នកក្នុងរយៈពេល 3 សប្តាហ៍ ។ លទ្ធផលទាំងនេះ ក៏នឹងត្រូវផ្ញើទៅគ្រូពេទ្យ ឬអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកផងដែរ លើកលែងតែអ្នកប្រាប់យើងកុំឲ្យផ្ញើរកំឡុងពេលណាត់ជួបនោះ ។ សូមទូរស័ព្ទទៅលេខ **0800 270 200** ដោយឥតគិតថ្លៃ ប្រសិនអ្នកនៅមិនទាន់ទទួលបានលទ្ធផលតាមកាលកំណត់ទេនោះ ។

នៅពេលដែលដល់ពេលត្រូវទៅពិនិត្យលើកក្រោយ អ្នកនឹងទទួលបានលិខិតអញ្ជើញតាមរយៈអ៊ីមែល សារជាអក្សរ ឬសំបុត្រ ជាមួយនឹងតំណភ្ជាប់កក់ផ្ទាល់ខ្លួនដែលមានសុវត្ថិភាព ។

សម្រាប់ស្ត្រីភាគច្រើន ការទៅពិនិត្យលើកក្រោយ គឺក្នុងរយៈពេល 2 ឆ្នាំ ។ វាអាចខុសគ្នាសម្រាប់ស្ត្រីដែលមានអាយុចន្លោះពី 70 ទៅ 74 ឆ្នាំដែលចូលរួមកម្មវិធីឡើងវិញ ដោយសារតែអាយុត្រូវមកពិនិត្យត្រូវបានពង្រីក ។

សូមស្វែងយល់បន្ថែមអំពីការពិនិត្យសុដន់សម្រាប់ស្ត្រីដែលមានអាយុពី 70 ឆ្នាំ ឡើងទៅនៅឯ **TimeToBreastScreen.nz** ។

ការមកពិនិត្យជាប្រចាំមានសារៈសំខាន់ ដើម្បីឱ្យមានឱកាសរកឃើញការប្រែប្រួល ណាមួយ នៅដំណាក់កាលដំបូង ដែលងាយស្រួលក្នុងការព្យាបាល។

ពេលខ្លះយើងបានមើលឃើញអ្វីមួយនៅក្នុងរូបថតកាំរស្មីអ៊ិចរបស់អ្នក ដែលត្រូវការ ពិនិត្យបន្ថែមឱ្យកាន់តែច្បាស់ ។ ព័ត៌មានបន្ថែមនឹងត្រូវបានផ្តល់ជូនអ្នក ប្រសិនបើអ្នកត្រូវ ត្រឡប់មកវិញសម្រាប់ការពិនិត្យបន្ថែម ។ សូមចងចាំថា នេះមិនមែនមានន័យថា អ្នកមាន ជំងឺមហារីកសុដន់នៅក្នុងខ្លួនឡើយ គឺគេគ្រាន់តែត្រូវការព័ត៌មានបន្ថែម ប៉ុណ្ណោះ ។

វាជាជម្រើសរបស់អ្នក

វាជាជម្រើសរបស់អ្នក ថាតើអ្នកចង់ថតម៉ាម៉ូក្រាមជាប្រចាំដែរឬទេ ដើម្បីពិនិត្យរកមើល ជំងឺមហារីកសុដន់របស់អ្នក ។ អ្នកអាចចាកចេញពីកម្មវិធីនេះ នៅពេលណាក៏បាន ។ អ្នក ក៏អាចចូលរួមក្នុងកម្មវិធីនេះឡើងវិញ នៅពេលណាក៏បានដែរ ដរាបណាអ្នកនៅតែមាន សិទ្ធិទទួលបានសេវាកម្មនេះ។

ប្រសិនបើអ្នកសម្រេចចិត្តមិនចូលរួមក្នុងកម្មវិធីនេះ អ្នក ឬអ្នកផ្តល់សេវាថែទាំសុខភាព របស់អ្នក នៅតែអាចរៀបចំការថតម៉ាម៉ូក្រាមរបស់អ្នកជាមួយសេវាកម្មផ្សេងទៀត ប៉ុន្តែ អាចមិនមែនជាការថតជូនដោយឥតគិតថ្លៃឡើយ ហើយលទ្ធផលនោះ នឹងមិនត្រូវបាន កត់ត្រាទុកជាមួយ BreastScreen Aotearoa ឡើយ ។

វាជាការទទួលខុសត្រូវរបស់កម្មវិធី ក្នុងការផ្តល់ការថែទាំដ៏ល្អបំផុតដល់អ្នកចូលរួម ។ ប្រសិនបើ នៅពេលណាមួយ អ្នកមានអារម្មណ៍មិនសុខស្រួល ឬមិនសប្បាយចិត្ត ជាមួយនឹងការថែទាំដែលអ្នកបានទទួល សូមប្រាប់យើងឱ្យដឹង ។ វាមានសារៈសំខាន់ សម្រាប់យើងដែលអ្នកបន្តត្រឡប់មកថតម៉ាម៉ូក្រាមជាប្រចាំ ដូច្នេះប្រសិនបើមានបញ្ហា ណាមួយ យើងនឹងខិតខំប្រឹងប្រែងអស់ពីសមត្ថភាព ដើម្បីដោះស្រាយបញ្ហានោះ។

អ្នកអាចស្វែងយល់បន្ថែមអំពីសិទ្ធិរបស់អ្នកនៅឯ **hdc.org.nz/your-rights**

Scan the QR code to access available translations of BSA brochures into languages other than English and formats including Braille, audio, Large Print, Easy Read and NZSL.

សូមចងចាំ

- ការថតម៉ាម៉ូក្រាម មិនមែនជាការការពារជំងឺមហារីកឡើយ ប៉ុន្តែវាអាចជួយរកឃើញជំងឺនេះ ។
- ការថតម៉ាម៉ូក្រាម អាចរកឃើញជំងឺមហារីក ភាគច្រើនដែលមានវត្តមាននៅក្នុងខ្លួនអ្នក នៅពេលពិនិត្យសុដន់ ប៉ុន្តែ ប្រហែលជា ១០ ភាគរយនៃជំងឺមហារីកសុដន់ នឹងមិនអាចត្រូវបានថតឃើញទេ។

សញ្ញាដែលអាចកើតមាននៃជំងឺមហារីកសុដន់គឺ ៖

- មានដុំពកថ្មីចេញនៅក្នុងសុដន់ ឬក្លៀក
- ការផ្លាស់ប្តូររូបរាង ឬទំហំសុដន់
- ការផ្លាស់ប្តូរស្បែកសុដន់ ដូចជា ការខូច ការជ្រីវចូល ឬ ការឡើងក្រាស់
- ការផ្លាស់ប្តូរនៅក្បាលសុដន់ ដូចជាក្បាលសុដន់ងាកចូលក្នុង ដំបៅ ឬការរមាស់ថ្មី
- ការហូរទឹករំអិល ឬការហូរឈាមពីក្បាលសុដន់
- ការឡើងក្រហមមិនបាត់
- ឈឺចាប់ក្នុងសុដន់ មិនរសាយ ។

ខណៈពេលដែលសញ្ញាទាំងនេះ អាចមិនមែនជាសញ្ញានៃជំងឺមហារីកសុដន់ក៏ដោយ ក៏ជាការសំខាន់ ដែលការផ្លាស់ប្តូរថ្មីនៃសុដន់ ត្រូវបានពិនិត្យដោយអ្នកផ្តល់សេវាថែទាំសុខភាពរបស់អ្នកឱ្យបានឆាប់បំផុត ។

ប្រសិនបើការថតម៉ាម៉ូក្រាម នៅថ្ងៃនេះមានការឈឺចាប់ វាមានសារៈសំខាន់ណាស់ក្នុងការប្រាប់បុគ្គលិកនៅ BreastScreen Aotearoa អំពីបញ្ហានេះ មុនពេលអ្នកត្រឡប់មកថតម៉ាម៉ូក្រាមលើកក្រោយ ។ ពួកគេអាចជួយធ្វើឲ្យអ្នក មានអារម្មណ៍សុខស្រួលជាងនេះ ចំពោះការថតនៅពេលក្រោយ ។

យើងខ្ញុំសូមស្វាគមន៍ចំពោះមតិយោបល់ណាមួយអំពីការមកថតនៅថ្ងៃនេះ ហើយសូមលើកទឹកចិត្តអ្នកឱ្យប្រាប់មិត្តភក្តិរបស់អ្នកអំពីកម្មវិធីនេះ ។ យើងខ្ញុំសង្ឃឹមថានឹងបានជួបអ្នកម្តងទៀតក្នុងរយៈពេល 2 ឆ្នាំ ខាងមុខ ។

Time to screen BreastScreen Aotearoa

Health New Zealand
Te Whatu Ora

Te Kāwanatanga o Aotearoa
New Zealand Government

This resource is available from **healthed.govt.nz** or your local Authorised Provider. Revised September 2026. **HE10117-KHM**